# ឯកសារសង្ខេបអំពីដៃគូអនុវត្តជាយុទ្ធសាស្ត្រ
# ផ្នែកពិការភាព

## សង្ខេបគម្រោង

គម្រោងនេះនឹងកសាងនូវសមិទ្ធិផល និងមេរៀនល្អៗដែលទទួលបានពីកម្មវិធី ACCESS ដំណាក់កាលទី១ ដែលមានប្រសិទ្ធភាពក្នុងការពង្រឹងនូវទំនាក់ទំនង ស្តង់ដារនៃការផ្តល់សេវា និងសមត្ថភាពបច្ចេកទេសរបស់អង្គការជនពិការកម្ពុជា (CDPO) និងអង្គការតំណាងជនមានពិការភាព (OPDs) ដែលដឹកនាំដោយស្ត្រី និងយុវជន ទៅលើបរិយាបន្នពិការភាព ការស្វែងរកការគាំទ្រ ការអភិវឌ្ឍន៍ និងគ្រប់គ្រង ស្ថាប័ន និងការបង្កើនលទ្ធភាពក្នុងការទទួលបានសេវាចាំបាច់ផ្សេងៗ រួមទាំងកម្មវិធីកិច្ចគាំពារសង្គម។

អង្គការជនពិការកម្ពុជា នឹងធ្វើការសហការជាមួយដៃគូរដ្ឋាភិបាលនានា អង្គការមិនមែនរដ្ឋាភិបាលនៅថ្នាក់ជាតិ និងផ្តល់ការកសាងសមត្ថភាពដល់បណ្តាញអង្គការតំណាងជនមានពិការភាពរបស់ខ្លួនទូទាំងប្រទេស ជាពិសេសអង្គការតំណាងជនមានពិការភាព ដែលដឹកនាំដោយស្ត្រី និងយុវជន ដើម្បីធ្វើការប្រកបដោយប្រសិទ្ធភាពនៅថ្នាក់ក្រោមជាតិ ក្នុងន័យស្វែងរកមតិគាំទ្រដើម្បីទទួលបាននូវកិច្ចគាំពារសង្គម ធ្វើឱ្យប្រសើរឡើងនូវផែនការវិនិយោគឃុំ/សង្កាត់ប្រកបដោយបរិយាបន្ន និងសេវាចាំបាច់នានា។

## លទ្ធផលរំពឹងទុករបស់គម្រោង

១. ពង្រឹងសមត្ថភាព និងការសម្របសម្រួលរបស់ OPDs ជាពិសេស OPDs ដែលដឹកនាំដោយស្ត្រី និងយុវជន ដើម្បីស្វែងរកការគាំទ្រសម្រាប់បរិយាបន្នពិការភាព និងកិច្ចគាំពារសង្គមនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

២. បង្កើនចំណេះដឹង និងការយល់ដឹងដល់មន្ត្រីរៀបចំគោលនយោបាយ អ្នកផ្តល់សេវា និងសាធារណៈជន លើបញ្ហាទាក់ទងនឹងពិការភាព រួមទាំងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពដំណាក់កាលទី៣ កម្មវិធីគាំពារសង្គម និងសិទ្ធិជនមានពិការភាព ស្ត្រី កុមារ និងអ្នកដែលមានបញ្ហាអូទីស្សឹម។

| សកម្មភាពសំខាន់ៗ |
|---|
| ១. សម្របសម្រួលរវាងកម្មវិធី ACCESS 2 និង កម្មវិធីដែលផ្តល់មូលនិធិដោយ DFAT ដូចជា កម្មវិធី «ពន្លកចំណេះ»៖ ដើម្បីស្វែងរកជំនួយបច្ចេកទេសសម្រាប់ការវិភាគលើបរិយាបន្នពិការភាពនៅក្នុងប្រព័ន្ធគាំពារសង្គមរបស់កម្ពុជា ដោយប្រើប្រាស់ទិន្នន័យពីអង្គការតំណាងជនមានពិការភាព រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល (NGOs) ។<br>២. រៀបចំកិច្ចប្រជុំប្រចាំត្រីមាសសម្រាប់ OPDs ៖ ជំរុញការយល់ដឹងរួមគ្នាអំពីកិច្ចគាំពារសង្គមប្រកបដោយបរិយាបន្នពិការភាព តាមរយៈការសម្របសម្រួលកិច្ចសន្ទនាគោលនយោបាយរវាង OPDs និងដៃគូរដ្ឋាភិបាល។<br>៣. អង្គការតំណាងជនមានពិការភាព ដែលដឹកនាំដោយយុវជន៖ ពង្រឹង និងធ្វើឱ្យមាននិរន្តរភាពបណ្តាញ អង្គការតំណាងជនមានពិការភាពទូទាំងប្រទេស សហការជាមួយវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API) សម្រាប់ការកសាងសមត្ថភាព ការស្វែងរកមតិគាំទ្រ និងការធ្វើបច្ចុប្បន្នភាពកិច្ចគាំពារសង្គម។<br>៤. លើកកម្ពស់តួនាទី និងការប្រាស្រ័យទាក់ទងរបស់ OPDs ៖ ធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានព័ត៌មានតាមរយៈវិទ្យុសម្លេងជនមានពិការភាព (VPD) គាំទ្រជំនាញការគ្រប់គ្រងទិន្នន័យ និងទំនាក់ទំនងសម្រាប់ OPDs ។<br>៥. ពង្រឹងការយល់ដឹង និងការស្វែងរកមតិគាំទ្រ៖ រៀបចំយុទ្ធនាការ និងព្រឹត្តិការណ៍នានាទាក់ទងនឹងបញ្ហាពិការភាព បង្កើត និងផ្សព្វផ្សាយនូវឧបករណ៍ព័ត៌មាន។<br>៦. កសាងបណ្តាញ៖ បង្កើតភាពជាដៃគូជាមួយអ្នកពាក់ព័ន្ធ (អង្គការបណ្តាញជនមានពិការភាព អង្គការមិនមែនរដ្ឋាភិបាល ប្រព័ន្ធផ្សព្វផ្សាយ និង ស្ថាប័នអប់រំ) ដើម្បីលើកកម្ពស់បញ្ហាពិការភាព និងចែករំលែកការអនុវត្តល្អៗ។<br>៧. ផ្តល់ភាពអង់អាច៖ ធ្វើឱ្យមានការចូលរួមរបស់ជនមានពិការភាព (រួមទាំងស្ត្រី កុមារ និងអ្នកដែលមានបញ្ហាអូទីស្សឹម) ក្នុងការសម្រេចចិត្ត និងការតស៊ូមតិ។ |
| **អ្នកទទួលផល** |
| ១. ដោយផ្ទាល់៖ OPDs ចំនួន ៧៧ រួមទាំងវេទិកាស្ត្រី និងកុមារពិការ (OPDs ដឹកនាំដោយយុវជន និង ដឹកនាំដោយស្ត្រី) ទទួលបានចំណេះដឹងអំពីវិធីសាស្ត្រថ្មីៗស្តីពីកិច្ចគាំពារសង្គមប្រកបដោយបរិយាបន្ន និងកម្មវិធីវិនិយោគឃុំ/សង្កាត់ និងការអនុវត្តការងារគណនេយ្យភាពសង្គម(CIP/ISAF) ។<br>២. ដោយប្រយោល៖ ក្រុមជួយខ្លួនឯង(SHG) ចំនួន ១០០០នាក់  ដែលមានពិការភាពគ្រប់ប្រភេទ របស់អង្គការតំណាងជនមានពិការភាព /វេទិកាស្ត្រី និងកុមារពិការ ទាំង៧៦ គឺជាអ្នកទទួលផលដោយប្រយោល។ សមាជិកជនមានពិការភាពទាំងអស់នៅក្នុងរាជធានីខេត្តទាំង២៥ និងគ្រួសាររបស់ពួកគេនឹងកើនឡើងការយល់ដឹងអំពីកិច្ចគាំពារសង្គមប្រកបដោយបរិយាបន្ន ប័ណ្ណសមធម៌ ប័ណ្ណសម្គាល់ពិការភាព និងកម្មវិធីវិនិយោគឃុំ សង្កាត់។ អាជ្ញាធរនៅថ្នាក់ក្រោមជាតិនឹងយល់ដឹងអំពីបរិយាបន្នពិការភាព។ |

| |
|---|
| **តំបន់គោលដៅ** |
| ខេត្តគោលដៅសំខាន់ៗរួមមាន កំពង់ស្ពឺ សៀមរាប កំពង់ចាម និងរតនគិរី និង OPDs នៅទូទាំងប្រទេស។ |
| **ដៃគូអនុវត្តគម្រោង** |
| ស្ថាប័នរដ្ឋាភិបាល៖ ក្រុមប្រឹក្សាសកម្មភាពជនពិការ (DAC) មូលនិធិជាតិជំនួយសង្គម (NSAF) នាយកដ្ឋានសុខុមាលភាពជនពិការ (DWPD) នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (MoSVY) នាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៃក្រសួង ផែនការ (MoP) អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម (GS-NSPC) គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.អ.ប) នៃក្រសួងមហាផ្ទៃ (MOI)។ អង្គការមិនមែនរដ្ឋាភិបាល៖ វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ |
| **រយៈពេលអនុវត្តគម្រោង** |
| ខែមករា ឆ្នាំ២០២៤ រហូតដល់ ខែមិថុនា ឆ្នាំ២០២៨ |
| **ព័ត៌មានទំនាក់ទំនង** |

| | |
|---|---|
| អង្គការជនពិការកម្ពុជា<br>លោកស្រី ម៉ាក់ ម៉ូនីកា<br>នាយិកាប្រតិបត្តិ<br>ទូរស័ព្ទលេខ៖ (៨៥៥) ១៦ / ៧៧ ៨០០ ៥៧២<br>អ៊ីម៉ែល៖ monika.mak@cdpo.org<br>ឬ director@cdpo.org | កម្មវិធី ACCESS 2<br>វេជ្ជបណ្ឌិត ជូ វិវឌ្ឍន៍<br>ប្រធានផ្នែកពិការភាព និងស្តារលទ្ធភាពពលកម្ម<br>ទូរស័ព្ទលេខ៖ (៨៥៥) ១២ ៩១៥ ៦៧៤<br>អ៊ីម៉ែល៖ Vivath.Chou@access2cambodia.org |

គម្រោងនេះ ឧបត្ថម្ភដោយរដ្ឋាភិបាលអូស្ត្រាលីតាមរយៈកម្មវិធីសហប្រតិបត្តិការអូស្ត្រាលី-កម្ពុជាដើម្បីសេវាប្រកបដោយនិរន្តរភាព និងសមធម៌ - ដំណាក់កាលទី២ (ACCESS 2)។

ខែមីនា ឆ្នាំ២០២៤